# កម្ពុជា: ការពិនិត្យស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ពីឆ្នាំ២០០៧ ដល់រយៈពេលមធ្យម- សូចនាករសំខាន់ៗនៃកំណើន ការអភិវឌ្ឍន៍ និង វិបុលភាពរួម

*អេង នេត្រា និង ភីម រុនស៊ីណារិទ្ធិ បានសង្ខេប និងធ្វើសំយោគបទបង្ហាញរបស់តំណាងមកពី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (MEF) មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និងវិទ្យាស្ថាន វបសអ- CDRI ។**

កម្ពុជាបានទទួលសន្តិភាព និងស្ថិរភាពប្រសើរឡើងនៅទសវត្សរ៍ចុងក្រោយនេះ ហើយបានចាប់អនុវត្តគំនិតផ្តួចផ្តើមថ្មីជាច្រើន ដូចជា សេរីភាវូបនីយកម្មសេដ្ឋកិច្ច កំណែទំរង់ស្ថាប័ន កំណែទំរង់នយោបាយ ដើម្បីឆ្លើយតបទៅនឹងបំរែបំរួលសេដ្ឋកិច្ចនយោបាយ ។ កម្ពុជាបានរៀបចំ និងគ្រប់គ្រងការបោះឆ្នោត និងបង្កើតស្ថាប័នរដ្ឋ ហើយថ្មីៗនេះបានអនុវត្តដោយជោគជ័យនូវការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់អាណត្តិទីពីរ ដែលជាផ្នែកមួយនៃដំណើរការវិមជ្ឈការនៅប្រទេសកម្ពុជា ។

កម្ពុជាបានកែលំអសេវាសង្គមចំបងៗ ដូចជា ការថែទាំសុខភាព អប់រំ ហេដ្ឋារចនាសម្ព័ន្ធជនបទ និងប្រព័ន្ធស្រោចស្រព ។ សេដ្ឋកិច្ចមានដំណើរការល្អណាស់ ប៉ុន្តែការកាត់បន្ថយភាពក្រីក្រ ការគ្រប់គ្រងធនធានធម្មជាតិ និងអភិបាលកិច្ច នៅតែជាបញ្ហាប្រឈម ។ យោងតាមបទបង្ហាញ នៅវគ្គទីមួយនៃសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០០៧ របស់តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មូលនិធិរូបិយវត្ថុអន្តរជាតិ និងវិទ្យាស្ថាន CDRI អត្ថបទនេះបានសង្ខេប និងធ្វើសំយោគ នូវជោគជ័យនៃការអភិវឌ្ឍន៍ និងបញ្ហាប្រឈមចំបងៗ មានទាំងកំណើនសេដ្ឋកិច្ច រហូតដល់អភិបាលកិច្ច ។

* អត្ថបទនេះរៀបរៀងឡើង ដោយផ្អែកលើបទបង្ហាញរបស់លោកបណ្ឌិត ហង់ ជួនណារ៉ុន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក John Nelms តំណាងមូលនិធិរូបិយវត្ថុអន្តរជាតិ IMF ប្រចាំនៅកម្ពុជា និងលោកស្រី អេង នេត្រា អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI នៅសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០០៧ ។ លោក ភីម រុនស៊ីណារិទ្ធិ ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ។

## ការអភិវឌ្ឍន៍ម៉ាក្រូសេដ្ឋកិច្ច: លទ្ធផលថ្មីៗ និងចក្ខុវិស័យរយៈពេលមធ្យម

*ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើបទបង្ហាញផ្តោតជាសំខាន់លើបញ្ហាសេដ្ឋកិច្ចចំបងៗ ដែលកម្ពុជាកំពុងប្រឈម ដូចជា លទ្ធផលម៉ាក្រូសេដ្ឋកិច្ច ការវិវត្តន៍ខាងសារពើពន្ធ លទ្ធផលក្នុងវិស័យហិរញ្ញវត្ថុ និងចក្ខុវិស័យលើកំណើនសេដ្ឋកិច្ចទូទៅ សំរាប់ឆ្នាំ២០០៧-២០១៥ ។ ខាងក្រោម ជាសេចក្តីសង្ខេបនៃបញ្ហាទាំងនេះ ។*

*ក្រាហ្វិក ១: អត្រាកំណើនសេដ្ឋកិច្ចឆ្នាំ២០០២-២០១០*




*r=បានពិនិត្យឡើងវិញ e=ប៉ាន់ស្មាន p=ព្យាករណ៍*

*ប្រភព: ហង់ ជួនណារ៉ុន*

កម្ពុជាមានការរីកចំរើន និងស្ថិរភាពខាងម៉ាក្រូសេដ្ឋកិច្ចគួរឱ្យកត់សំគាល់ ព្រមទាំងកំណើនសេដ្ឋកិច្ចដ៏រឹងមាំ ជាមធ្យម ៨,៧% ក្នុងមួយឆ្នាំនាទសវត្សរ៍ចុងក្រោយ ។ ផលិតផលក្នុងស្រុកសរុប (ផសស) ពិត កើន ១០,៤% នៅឆ្នាំ២០០៦ (ក្រាហ្វិក ១) ដោយសារជាសំខាន់មកពីការរីកចំរើនខាងការនាំចេញផលិតផលកាត់ដេរ វិស័យទេសចរណ៍ និងសកម្មភាពសាងសង់ ។ ការនាំចេញផលិតផលកាត់ដេរកម្ពុជា កើន ២០% នៅឆ្នាំ២០០៦ ដល់ ២,៥ពាន់លានដុល្លារ និងផ្តល់ការងារចំនួន ៣៣៤.០០០ ។ សហរដ្ឋអាមេរិកជាអតិថិជនសំខាន់ជាងគេ ដោយបានទទួលទិញ ៧១% បន្ទាប់មកតំបន់អឺរ៉ូ ២៣% និងកាណាដា ៤% ។ ទេសចរណ៍ និងសកម្មភាពសាងសង់ នៅតែខ្លាំងក្លាដដែលនៅឆ្នាំ២០០៦ ។ ចំនួនភ្ញៀវទេសចរ បានរួមចំណែកយ៉ាងសំខាន់ធ្វើអោយផសស កើនដល់ ១,៧លានដុល្លារ ។ ផ្ទះល្វែងថ្មីៗសាងសង់នៅភ្នំពេញ កំពុងកើនឡើងពី ៨០០០ ទៅ ១០០០០ផ្ទះ ជារៀងរាល់ឆ្នាំ ហើយគំរោងទីក្រុងថ្មីមួយនៅបឹងពោងពាយ បានចាប់ផ្តើមនៅឆ្នាំ២០០៦ ។ ក្រុមហ៊ុនចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម មានសរុប ១១.៥៨៤ក្រុមហ៊ុន ក្នុងនេះ ១៦០០ ជាក្រុមហ៊ុនចុះបញ្ជីថ្មីនៅឆ្នាំ២០០៦ ។

នៅឆ្នាំ២០០៦ លទ្ធផលសារពើពន្ធកើនឡើង ដោយសារការប្រមូលចំណូល និងសនិទានកម្មចំណាយ បានកាន់តែប្រសើរ ។ អតិរេកថវិកាចរន្តកើនដល់ ១,៨% នៃ ផសស ហើយឱនភាពថវិកាទូទៅ ធ្លាក់ចុះមកត្រឹម ១,៧% នៃ ផសស ។ ចំណូលសរុបកើនពី ៦៦០លានដុល្លារអាមេរិកនៅឆ្នាំ២០០៥ ដល់ ៨៣២លានដុល្លារអាមេរិកនៅឆ្នាំ២០០៦ ដោយសារកំណើនការប្រមូលចំណូលពន្ធ និងចំណូលមិនមែនពន្ធ ។ ចំណាយសរុប កើនឡើងពី ៨៥៣លានដុល្លារអាមេរិក នៅឆ្នាំ២០០៥ ដល់ ៩៥៩លានដុល្លារអាមេរិកនៅឆ្នាំ២០០៦ ក្នុងនេះ ការអភិវឌ្ឍន៍ហេដ្ឋា

រថនាសម្ព័ន្ធ គឺជាវិស័យអាទិភាព ដោយត្រូវចំណាយថវិកាអស់ ៤៥លានដុល្លារអាមេរិក ។ កំណើនសេដ្ឋកិច្ចរឹងមាំ និងការវិនិយោគខ្លាំងក្លាលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសហេដ្ឋារចនាសម្ព័ន្ធជនបទ ក៏នាំឱ្យមានការរីកចំរើនគួរកត់សំគាល់ដែរ ក្នុងវិស័យសង្គមកិច្ច ដូចជាការថយចុះនៃអត្រាមរណៈកុមារ និងកំណើន អត្រាអក្ខរកម្ម ។

វិស័យហិរញ្ញវត្ថុនៅកម្ពុជា លូតលាស់បានល្អនៅឆ្នាំ២០០៦ ។ រូបិយវត្ថុទូទៅ (M2) កើនបាន ៣៨% ធៀបនឹងកំណើន ១៦% នៅឆ្នាំ២០០៥ ដោយសារកំណើនការជឿទុកចិត្តលើប្រព័ន្ធធនាគារ ដែលជាលទ្ធផលនៃកំណែទំរង់ធនាគារ ។ បញ្ញើរូបិយវត្ថុបរទេស កើន ៤៥% និងឥណទានធនាគារចំពោះវិស័យឯកជន កើន ៥១% ។ ការរីកចំរើននៃមីក្រូហិរញ្ញវត្ថុក៏គួរឱ្យកត់សំគាល់ដែរ ។ កំចីមីក្រូហិរញ្ញវត្ថុ កើន ៤០% ដល់ ៥៦លានដុល្លារនៅឆ្នាំ២០០៥ ។ តាមការបាន់ស្មាន លំហូរវិនិយោគផ្ទាល់បរទេសមានចំនួន ៣៩៤លានដុល្លារ នៅឆ្នាំ២០០៦ ធៀបនឹង ៣៨១លានដុល្លារ នៅឆ្នាំ២០០៥ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានអនុម័ត ៨៨គំរោងវិនិយោគ មានទឹកប្រាក់សរុប ៣,៨ពាន់លានដុល្លារ ដែលគេរំពឹងថា នឹងបង្កើតបាន ១៥៤.000ការងារ បើសិនអនុវត្តបានពេញលេញ ។

សេដ្ឋកិច្ចប្រទេសកម្ពុជាមានអនាគតភ្លឺស្វាងល្អណាស់ ។ នៅក្នុងរយៈពេលមធ្យម ផសស រំពឹងថានឹងកើន ៩% នៅឆ្នាំ២០០៧ និង ៧-៨% នៅឆ្នាំ២០០៨-០៩ នៅក្នុងនេះ វិស័យទេសចរណ៍ ឧស្សាហកម្មកាត់ដេរ និងសកម្មភាពសាងសង់ នៅតែជាសសរទ្រូងនៃកំណើន ហើយកសិកម្មមានតួនាទីជួយទ្រទ្រង់ ។ នៅក្នុងរយៈពេលវែង ផលិតផលក្នុងស្រុកសរុប (ផសស) រំពឹងថានឹងរីកលូតលាស់ ៩-១០% នៅឆ្នាំ២០១០-១៥ ។ ចាប់ពីឆ្នាំ២០១០ ចំណូលពីប្រេងកាត នឹងក្លាយជាប្រភពថ្មីមួយនៃកំណើន ហើយដើរតួនាទីយ៉ាងសំខាន់ជួយរក្សាអត្រាកំណើនដ៏ខ្ពស់នេះ ។ ថ្វីបើវិស័យកាត់ដេរ ទេសចរណ៍ និងសំណង់ នៅតែបន្តជំរុញកំណើន កម្ពុជាត្រូវធ្វើចំរុះកម្មប្រភពកំណើន ដោយកសាងឧស្សាហកម្មថ្មីៗ ដើម្បីធ្វើអោយកំណើនកាន់តែមានមូលដ្ឋានធំទូលាយ ។

ទន្ទឹមនឹងនេះដែរ វាទាមទារអោយមានកំណែទំរង់គោលនយោបាយគ្រប់ជ្រុងជ្រោយ សំដៅធ្វើអោយការវិនិយោគនៅប្រទេសកម្ពុជាកាន់តែមានលក្ខណៈទាក់ទាញ ។ ដើម្បីសំរួលដល់សកម្មភាពពាណិជ្ជកម្ម គេត្រូវដោះស្រាយបញ្ហាកាត់បន្ថយថ្លៃប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ អគ្គិសនី កំពង់ផែ និងកំរៃមិនផ្លូវការផ្សេងៗ ហើយគួរបង្កើតតំបន់កែច្នៃសេដ្ឋកិច្ច (economic processing zones) ដើម្បីទាក់ទាញវិនិយោគទុនពីបរទេស ។

កំណែទំរង់សម្បទានសេដ្ឋកិច្ចមិនដំណើរការ កំណែទំរង់ដីដើម្បីទប់ស្កាត់ការរំលោភយកដីធ្លីពីជនជាតិភាគតិច គោលនយោបាយបង្កើនលទ្ធភាព កសិករក្នុងការទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសគ្រាប់ពូជល្អៗ មីក្រូហិរញ្ញវត្ថុ អគ្គិសនី និងប្រព័ន្ធស្រោចស្រព គឺជាកត្តាចាំបាច់សំរាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ។ ម្យ៉ាងទៀត ដើម្បីទ្រទ្រង់កំណើនក្នុងវិស័យនេះ ការធ្វើចំរុះកម្មផលិតផលកសិកម្ម ការម៉ៅការឱ្យផ្សព្វផ្សាយពី ផលិតផលម៉ាស៊ីននិងសេវាកម្មប្រភេទខ្លះ ដូចជា ប្រតិបត្តិការការិយាល័យនៅជួរក្រោយ (back office operations) ផ្នែកធនាគារ គណនេយ្យ និងផ្នែកផ្សេងៗទៀត ហើយការជំរុញអាជីវកម្មកែច្នៃផលិតផលកសិកម្ម និងការបង្កើតអង្គការកសិករ ក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ។

*លោក John Nelmes តំណាង IMF ប្រចាំនៅកម្ពុជា បានធ្វើបទបង្ហាញផ្តល់មតិអំពីការវិវត្តន៍ម៉ាក្រូសេដ្ឋកិច្ចកម្ពុជានាពេលថ្មីៗ និងចក្ខុវិស័យសំរាប់ឆ្នាំ២០០៧ និងរយៈពេលមធ្យម ដែលមានជាសង្ខេបដូចតទៅ:*

*ក្រាហ្វិក ២: សមាភាគនៃអត្រាកំណើន ផសស ពិត*




*ប្រភព: John Nelmes*

សេដ្ឋកិច្ចកម្ពុជា ទោះបីមានមូលដ្ឋានតូចចង្អៀតក្តី ក៏មានកំណើនរឹងប៉ឹងនៅឆ្នាំ២០០៦ និងមានអតិផរណាទាប ។ កំណើន ផសស មានសន្ទុះលឿនជាងអត្រាកំណើនសំរាប់ពិភពលោកទាំងមូល និងប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ។ ការនាំចេញផលិតផលកាត់ដេរនៅតែខ្លាំងក្លា វិស័យទេសចរណ៍បានបន្តរីកចំរើន ហើយវិស័យកសិកម្ម និងនេសាទ ក៏មានកំណើនវិជ្ជមានដែរ (ក្រាហ្វិក ២) ។

ការវិវត្តន៍ទាំងនេះ មានការជួយទ្រទ្រង់ពីគោលនយោបាយសារពើពន្ធដ៏ប្រុងប្រយ័ត្នរបស់រដ្ឋាភិបាល ។ ក្នុងប៉ុន្មានឆ្នាំថ្មីៗ មានការរីកចំរើនក្នុងកិច្ចបង្កើនចំណូលរដ្ឋាភិបាលជាទូទៅ ។ ការពង្រឹងអនុវត្តន៍ខ្លាំងក្លានៃការប្រមូលពន្ធក្នុងស្រុក និងពន្ធគយ ព្រមទាំងបំណុលពន្ធយឺតយ៉ាវមិនទាន់បង់ និងចំណូលពីឯកជនភាវូបនីយកម្ម អាចជួយប៉ះប៉ូវលើសពីគ្រប់គ្រាន់នូវការធ្លាក់ចុះជាបន្តបន្ទាប់នៃចំណូលមិនមែនពន្ធ ។ ប៉ុន្តែ ការប្រមូលចំណូលនៅតែបានទាបជាខ្លាំងជាងប្រទេសឯទៀត ។

សកម្មភាពសេដ្ឋកិច្ចក្នុងប្រទេសបន្តរីកចំរើន ដោយសារការអនុវត្តន៍នយោបាយរូបិយវត្ថុដ៏ប្រុងប្រយ័ត្ន និងការធ្វើអន្តរការីកម្មហិរញ្ញវត្ថុ កាន់តែស៊ីជំរៅដោយវិស័យធនាគារ ។ អាជីវកម្មខ្នាតតូចដែលកាលពីមុនធ្វើប្រតិបត្តិការក្នុងវិស័យមិនផ្លូវការ កំពុងទៅចុះបញ្ជីកាន់តែច្រើនឡើង និងស្វែងរកហិរញ្ញវត្ថុពីធនាគារ ព្រមទាំងមានសកម្មភាពសាងសង់យ៉ាងខ្លាំងក្លា ដែលឆ្លុះបញ្ចាំងពីការរីកធំឡើងនៃតំរូវការវិនិយោគក្នុងផ្នែកអចលនទ្រព្យ ។

ចក្ខុវិស័យចំពោះម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យមនៅតែល្អប្រសើរ ។ សេដ្ឋកិច្ចរំពឹងថាមានកំណើនពិតប្រហែល ៩% នៅឆ្នាំ២០០៧ ដោយមានការបន្តរីកចំរើនក្នុងការនាំចេញផលិតផលកាត់ដេរ ទេសចរណ៍ និងសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ។ ក្នុងរយៈពេលមធ្យម កំណើនរំពឹងថា អាចមានចីរភាពនៅកំរិត ៧-៨% ។ ថ្វីបើប្រមើលមើលឃើញប្រសើរបែបនេះក្តី កម្ពុជាត្រូវប្រឹងប្រែងប្រមូលចំណូលបន្ថែម សំដៅបង្កើនអត្រាទាបជាប្រវត្តិសាស្ត្រនៃចំណូលធៀបនឹង ផសស សំរាប់ធ្វើហិរញ្ញប្បទានច្រើនថែមទៀតដល់ការចំណាយ ដើម្បីសំរេចគោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់កម្ពុជា និង

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ម្យ៉ាងទៀត ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ត្រូវធ្វើកំណែទំរង់ដ៏ចាំបាច់មួយចំនួន ។ ស្របជាមួយនឹងកំណើនចំណូលរដ្ឋ ត្រូវមានការបែងចែកចំណាយបន្ថែមទៀត ទៅអនុវត្តគំរោងមានផលិតភាព និងការកំណត់គោលដៅបានល្អខាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការថែទាំសុខភាព និងការអប់រំ ដើម្បីលើកស្ទួយជីវភាពរស់នៅ និងពង្រឹងផលិតភាព ។ សំខាន់ដូចគ្នាដែរ កម្ពុជាគួររៀបចំបរិយាកាសសេដ្ឋកិច្ចឱ្យអំណោយផលច្រើនដល់វិស័យឯកជន នឹងវិនិយោគបរទេស តាមរយៈការបន្តប្រឹងប្រែងជួយសំរួលពាណិជ្ជកម្ម និងកាត់បន្ថយទំងន់ហួសហេតុនៃរដ្ឋបាលសាធារណៈ ។

## ចក្ខុវិស័យវិទ្យាស្ថាន CDRI ចំពោះការអភិវឌ្ឍន៍ និងបញ្ហាប្រឈម

*លោកស្រី អេង នេត្រា ប្រធានស្រាវជ្រាវផ្នែកអភិបាលកិច្ចនៅ CDRI បង្ហាញលទ្ធផលស្រាវជ្រាវនៃកម្មវិធីស្រាវជ្រាវចំនួនបួនដែលមានសង្ខេបដូចតទៅៈ*

*ការកាត់បន្ថយភាពក្រីក្របានជឿនលឿនទៅមុខ ប៉ុន្តែវិសមភាពកើនឡើង*

ថ្វីបើមានកំណើនម៉ាក្រូសេដ្ឋកិច្ចជាទូទៅកំរិតខ្ពស់ ប៉ុន្តែនៅទសវត្សរ៍ចុងក្រោយនេះ កម្ពុជាសំរេចបានការកាត់បន្ថយភាពក្រីក្រប្រចាំឆ្នាំត្រឹមតែ ១% ប៉ុណ្ណោះ ។ ការសិក្សារបស់វិទ្យាស្ថាន CDRI លើភាពក្រីក្របង្ហាញថា កំណើននេះមិនបានចែកចាយប្រកបដោយសមធម៌ទេ ហើយគំលាតរវាងអ្នកមាន និងអ្នកក្រ តំបន់ជនបទនិងទីក្រុង បានកើនឡើង ។ តួនាទី និងការរួមចំណែករបស់ស្ត្រីចំពោះសេដ្ឋកិច្ច មានកាន់តែច្រើនឡើង ដោយសារបំរែបំរួលមូលដ្ឋានសេដ្ឋកិច្ច ទោះបីមានស្ត្រីក្រីក្របំផុតកាន់តែច្រើននាក់ កំពុងលក់កំលាំងពលកម្ម ធ្វើចំណាកស្រុកទៅរកការងារធ្វើ និងបំពេញភារកិច្ចរបស់បុរស បន្ថែមលើតួនាទីជាមេផ្ទះរបស់ខ្លួន ។

### ការគ្រប់គ្រងធនធានធម្មជាតិកំពុងធ្លាក់ចុះ

អ្នកក្រ និងអ្នកក្របំផុតកាន់តែច្រើននាក់ ត្រូវពឹងផ្អែកខ្លាំងឡើងៗលើធនធានធម្មជាតិ ជាពិសេស ផលព្រៃឈើ និងជលផល ប៉ុន្តែលទ្ធភាពប្រមូលយកផលកំពុងថយចុះគួរឱ្យកត់សំគាល់ ។ ការសិក្សារបស់វិទ្យាស្ថាន CDRI បង្ហាញថា អភិបាលកិច្ចធនធានធម្មជាតិវាសំខាន់បំផុត និងត្រូវគ្រប់គ្រងឱ្យមានចីរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ ពីព្រោះធនធានទាំងនោះគឺជាទ្រព្យសម្បត្តិចំបងគេសំរាប់អ្នកក្រ ។ ក្នុងសុន្ទរកថាបើកសន្និសីទ សម្តេចនាយករដ្ឋមន្ត្រី មានប្រសាសន៍ថា ការគ្រប់គ្រងដីធ្លីគឺជាអាទិភាពមួយរបស់សម្តេច ដើម្បីកាត់បន្ថយភាពក្រីក្រ ។ សុវត្ថិភាពកាន់កាប់ដី ជាបញ្ហាមួយសំខាន់បំផុតសំរាប់ប្រជាជនក្រីក្រនៅកម្ពុជា ។ ប្រជាជនក្រីក្រកាន់តែច្រើនកំពុងបាត់បង់ដី ដោយសារ "ការលក់ពេលមានអាសន្ន" បញ្ហាសុខភាព និងការរំលោភយកដី ។ វិទ្យាស្ថាន CDRI គាំទ្រយ៉ាងខ្លាំងដល់កិច្ចខំប្រឹងប្រែងចុះបញ្ជីដីធ្លី ប៉ុន្តែគួរពន្លឿនវាថែមទៀត និងផ្តោតលើតំបន់ទាំងឡាយណា ដែលជួយកាត់បន្ថយភាពក្រីក្របានច្រើនបំផុត ។

ការវាយតំលៃភាពក្រីក្រដោយមានការចូលរួម បង្ហាញថា ទោះបីជាដែននេសាទសហគមន៍អាចផ្តល់ប្រយោជន៍ដល់សហគមន៍មូលដ្ឋានក្តី ប៉ុន្តែប្រយោជន៍ទាំងនោះមិនបានបែងចែកមានសមភាពល្អឡើយ ។ តំបន់នេសាទដែលបើកចំហសំរាប់ជនទូទៅ បែរជាផ្តល់ប្រយោជន៍ច្រើន ដល់គ្រួសារអ្នកមាន និងអ្នកខាងក្រៅ (ដូចជា មន្ត្រីថ្នាក់ជាតិ និងឈ្មួញ) ទៅវិញ ។ ការស្រាវជ្រាវបង្ហាញទៀតថា ការគ្រប់គ្រងព្រៃធម្មជាតិធ្វើឡើងដោយថ្នាក់ជាតិ និងគ្មានការចូលរួមពីប្រជាជនមូលដ្ឋាន បានផ្តល់ផលប៉ះពាល់សេដ្ឋកិច្ចអវិជ្ជមានយ៉ាងច្រើនដល់សហគមន៍ ។ ជំរើសថ្មីៗនៃការគ្រប់គ្រងព្រៃឈើផ្អែកលើសហគមន៍ ត្រូវមានជាចាំបាច់ដើម្បីផ្តល់សមភាពក្នុងការប្រមូលផលព្រៃឈើ ។ បញ្ហាប្រឈមក្នុងការគ្រប់គ្រងធនធានធម្មជាតិមាន (១) អាណត្តិ និងសិទ្ធិអំណាចមិនច្បាស់លាស់ និងប្រទាំងប្រទើសគ្នា ដែលកាន់តែធ្ងន់ធ្ងរឡើងដោយសារដែនសមត្ថកិច្ចកំណត់មិនច្បាស់លាស់ (២) អំពើពុករលួយនៅថ្នាក់មូលដ្ឋាន ដែលរារាំងដល់ការពង្រឹងអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិ ស្តីពីលទ្ធភាពប្រើប្រាស់ និងការគ្រប់គ្រងធនធានធម្មជាតិ ។

### កំណែទំរង់ស្ថាប័នសំខាន់ៗសំរេចបានហើយ ប៉ុន្តែគណនេយ្យភាពនៅទន់ខ្សោយ

រដ្ឋាភិបាលកម្ពុជាអាចរក្សាបានស្ថិរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច ក្នុងទសវត្សរ៍ចុងក្រោយ ហើយបច្ចុប្បន្នកំពុងអនុវត្តបានល្អក្នុងការកាត់បន្ថយភាពក្រីក្រ និងកែលំអសេវាសាធារណៈ ។ ប៉ុន្តែជាទូទៅ រដ្ឋាភិបាលមិនទាន់មានលទ្ធភាពបង្កើតនីតិរដ្ឋប្រឆាំងអំពើពុករលួយ បង្កើតបរិយាកាសទាក់ទាញវិនិយោគិន រឺបង្កើតជាយន្តការគណនេយ្យភាពនៅឡើយទេ ។ ថ្វីបើសមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការកំពុងពង្រឹងទៀត ប៉ុន្តែអង្គការចាត់តាំងរបស់រដ្ឋនៅមិនទាន់ផ្សារភ្ជាប់គ្នាបានល្អទេ ។ ការពឹងផ្អែកលើការបង្គាប់បញ្ជាពីថ្នាក់លើមានកំរិតខ្ពស់ យន្តការគណនេយ្យភាពផ្លូវការនៅទន់ខ្សោយ ហើយការសំរបសំរួលយ៉ាងសក្តិសិទ្ធិនៅក្នុងក្រសួង នឹងរវាងក្រសួងនានាមានតិចតួចបំផុត ។

ការសិក្សារបស់វិទ្យាស្ថាន CDRI ក៏បង្ហាញដែរថា អាជ្ញាធរថ្នាក់ក្រោមជាតិនៅតែមានលក្ខណៈមជ្ឈការ និងពាក់ព័ន្ធនយោបាយកំរិតខ្ពស់ ។ ការគ្រប់គ្រងបែបមជ្ឈការ និងកង្វះខាតធនធាន ធ្វើអោយអាជ្ញាធរថ្នាក់ក្រោមជាតិទន់ខ្សោយ និងការគ្រប់គ្រងបុគ្គលិកនៅតាមមូលដ្ឋាន ការរៀបចំផែនការ និងការគ្រប់គ្រងចំណាយគ្មានប្រសិទ្ធភាព ។ ជាលទ្ធផល អ្នកគ្រប់គ្រងនៅមូលដ្ឋាន មិនអាចចាប់ឱ្យបុគ្គលិកខ្លួនមានគណនេយ្យភាពបានឡើយ ហើយពួកនោះជារឿយៗ ត្រូវបានអូសទាញដោយការងារ និងផលប្រយោជន៍ខាងក្រៅ ។ រឿងនេះធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមានលើសេដ្ឋកិច្ច និងប្រជាជន ជាពិសេសលើអ្នកក្រ និងអាជីវកម្មខ្នាតតូច ។ ស្ថាប័នរដ្ឋ មានសមត្ថភាពមិនទាន់គ្រប់គ្រាន់ដើម្បីជួយសំរួលឱ្យស្ត្រីបានចូលរួមធ្វើសេចក្តីសំរេចចិត្តនៅគ្រប់កំរិត និងដើម្បីឆ្លើយតបទៅនឹងតំរូវការរបស់ក្រុមងាយរងគ្រោះ ដូចជា អ្នកក្រ និងស្ត្រី ។

ក្រុមប្រឹក្សាឃុំបានផ្តល់សេចក្តីសង្ឃឹមខ្លះៗថា អាចកែលំអអភិបាលកិច្ចនៅថ្នាក់មូលដ្ឋានបាន ។ ការសិក្សារបស់វិទ្យាស្ថាន CDRI បង្ហាញថា ក្រុមប្រឹក្សាឃុំធ្វើការមានប្រសិទ្ធភាពល្អលើផ្នែកនានា ដូចជា ហេដ្ឋារចនាសម្ព័ន្ធជនបទដែលរួមមាន ការសាងសង់ផ្លូវ ប្រព័ន្ធស្រោចស្រព និងស្ពាន ។ អ្នកក្រក៏ទទួលបានប្រយោជន៍ផងដែរ ពីកិច្ចសហការរវាង NGOs និងក្រុមប្រឹក្សាឃុំ ។ ដោយសារក្រុមប្រឹក្សាឃុំមានធនធាន និងសិទ្ធិអំណាចតិចតួច ជាពិសេសនៅពេលដោះស្រាយបញ្ហាធនធានធម្មជាតិ រឺបញ្ហាពាក់ព័ន្ធនឹងតួអង្គខាងក្រៅដែលមានឥទ្ធិពល និងឋានៈខ្ពស់ជាង ពួកគេមិនមានលទ្ធភាពការពារនយោបាយប្រជាធិបតេយ្យ សេវាមានប្រសិទ្ធភាព រឺធនធានធម្មជាតិសំខាន់ៗឡើយ ។ រឿងនេះ ចង្អុលបង្ហាញពីសារៈសំខាន់ធំធេងនៃសមត្ថភាពគ្រប់គ្រងរដ្ឋបាល និងត្រិះរិះធ្វើសេចក្តីសំរេចចិត្ត ដែលនឹងមានចែងច្បាស់នៅក្នុងច្បាប់រៀបចំអង្គការនាពេលខាងមុខ ព្រមទាំងសារៈសំខាន់នៃទំនាក់ទំនងថ្នាក់ជាតិនិងថ្នាក់មូលដ្ឋាន និងអន្តរសកម្មភាពរវាងប្រព័ន្ធអភិបាលកិច្ចផ្លូវការ និងមិនផ្លូវការ ។

កម្មវិធីកំណែទំរង់ចំបងៗរបស់រដ្ឋាភិបាល ដូចជា វិមជ្ឈការនិងវិសហមជ្ឈការ

*តទៅទំព័រទី ១៤*